01213164

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 11 / 07 / 2016
ម៉ោង (Time/Heure): 13:35
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

E387/2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

## អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៦

**ជូនចំពោះ÷** គ្រប់ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី÷** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន÷** លោក/លោកស្រីចៅក្រម, មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ÷** សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី នួន ជា និងមេធាវីការពារក្តី ខៀវ សំផន អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធទៅនឹងសក្ខីកម្មរបស់អ្នកជំនាញ Alexander HINTON (2-TCE-88)

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើមួយពីមេធាវីការពារក្តី នួន ជា អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ("សំណើរបស់ នួន ជា") ដែលស្នើសុំឱ្យទទួលយកជាឯកសារភ័ស្តុតាងនូវឯកសារចំនួន ១៧ ដែលពាក់ព័ន្ធទៅនឹងការផ្តល់សក្ខីកម្មនាពេលខាងមុខរបស់លោក Alexander HINTON (2-TCE-88) ដែលបានដាក់នៅថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៦ (ឯកសារ E387)។ អង្គជំនុំជម្រះក៏បានទទួលសំណើរបស់មេធាវីការពារក្តី ខៀវ សំផន អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ("សំណើរបស់ ខៀវ សំផន") ដែលស្នើសុំឱ្យទទួលយកជាឯកសារភ័ស្តុតាងនូវឯកសារចំនួន ០៦ ដែលពាក់ព័ន្ធទៅនឹងការផ្តល់សក្ខីកម្មនាពេលខាងមុខរបស់លោក HINTON (ឯកសារ E387/1)។ អង្គជំនុំជម្រះបានស្តាប់សារណា

តបផ្ទាល់មាត់ទៅនឹងសំណើទាំងនេះ ក្នុងអំឡុងពេលសវនាការនៅថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១៦។

២. អង្គជំនុំជម្រះកត់សម្គាល់ថា ទាំងមេធាវីការពារក្តី នួន ជា និង មេធាវីការពារក្តី ខៀវ សំផន បានដាក់ការកែតម្រូវ ដែលធ្វើឱ្យមានការប្រែប្រួលដល់លេខឯកសារនៃឧបសម្ព័ន្ធនៃសំណើរបស់ នួន ជា និង សំណើរបស់ ខៀវ សំផន។ នៅក្នុងសេចក្តីសម្រេចនេះ អង្គជំនុំជម្រះប្រើប្រាស់លេខឯកសារនៃឧបសម្ព័ន្ធដែលបានកែតម្រូវរួច និងផ្តល់នូវការពិពណ៌នា ដើម្បីបញ្ជាក់។

៣. ទាក់ទងនឹងសំណើ E387 អង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតមួយផ្នែក និងទទួលយកឯកសារខាងក្រោម (លេខឯកសារថ្មីនៅក្នុងរង្វង់ក្រចក) ធ្វើជាឯកសារភស្តុតាង៖

ក. ឯកសារ E387.1.1 (E3/9702)–ប្រវត្តិការងាររបស់លោក Alexander HINTON។

ខ. ឯកសារ E387.1.3 (E3/9703) – "Mapping the Great Famine" ("ផែនទីស្តីពីមហាគ្រោះទុរ្ភិក្ស") Volodymyr Dibrova, *Ukrainian Weekly*, ចុះផ្សាយថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៣។

គ. ឯកសារ E387.1.2 (E3/9704) – "Anthropology, Cultural" ("នរវិទ្យា ផ្នែកវប្បធម៌") *Encyclopedia of Genocide and Crimes against Humanity*។

ឃ. ឯកសារ E387.1.4 (E3/9705) – DC-Cam, "Board of Directors and Advisors" (មជ្ឈមណ្ឌលឯកសារកម្ពុជា៖ "ក្រុមប្រឹក្សាភិបាល និងទីប្រឹក្សា")។

ង. ឯកសារ E387.1.5 (E3/9706) – "Cambodian Genocide Memory Project", ("គម្រោងស្តីពីការចងចាំនូវអំពើប្រល័យពូជសាសន៍នៅកម្ពុជា") Center for the Study of Genocide and Human Rights (មជ្ឈមណ្ឌលសិក្សាអំពើប្រល័យពូជសាសន៍ និងសិទ្ធិមនុស្ស)។

ច. ឯកសារ E387.1.6 (E3/9707) – "Director's Welcome" ("សេចក្តីស្វាគមន៍របស់នាយកមជ្ឈមណ្ឌល") Center for the Study of Genocide and Human Rights (មជ្ឈមណ្ឌលសិក្សាអំពើប្រល័យពូជសាសន៍ និងសិទ្ធិមនុស្ស)។

ឆ. ឯកសារ E387.1.7 (E3/9708) – "Hinton helped bring one of two major American archives of Khmer Rouge-related documents to the R-N campus

in 2005" ("លោក Hinton បានជួយនាំយកបណ្ណសារសំខាន់មួយក្នុងចំណោមបណ្ណសារសំខាន់ពីរនៃឯកសារដែលពាក់ព័ន្ធទៅនឹងរបបខ្មែរក្រហមទៅកាន់បរិវេណ R-N នៅឆ្នាំ ២០០៥") *Have You Met Rutgers-Newark?*។

ជ. ឯកសារ E387.1.8 (E3/9709) – ជីវប្រវត្តិរបស់លោក Alexander HINTON មហាវិទ្យាល័យ Newark នៃសាកលវិទ្យាល័យ Rutgers – គេហទំព័រ Newark។

ឈ. ឯកសារ E387.1.9 (E3/9710) – "Begrudgement, Reconciliation, and the Khmer Rouge" ("ការឈ្នានីស ការផ្សះផ្សារ និងពួកខ្មែរក្រហម") *Magazine of Documentation Center of Cambodia (ទស្សនាវដ្ដីមជ្ឈមណ្ឌលឯកសារកម្ពុជា)* លេខ ២០ ចុះផ្សាយខែ សីហា ឆ្នាំ ២០០១។

ញ. ឯកសារ E387.1.10 (E3/9711) – "Why did they kill? (1)" ("ហេតុអ្វីបានជាពួកគេសម្លាប់?(១)") Alex Hinton *កាសែតភ្នំពេញប៉ុស្តិ៍* ចុះផ្សាយថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៥។

ដ. ឯកសារ E387.1.11 (E3/9712) – "Opinion: Is there justice in Cambodia?" ("មតិយោបល់៖ តើមានយុត្តិធម៌នៅកម្ពុជាឬទេ?") Alex Hinton *កាសែតភ្នំពេញប៉ុស្តិ៍* ចុះផ្សាយថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១។

ឋ. ឯកសារ E387.1.12 (E3/9713) – "Time running out for Khmer Rouge tribunals" ("អស់ពេលវេលាសម្រាប់តុលាការខ្មែរក្រហមហើយ") Tom Fawthrop *កាសែត Al-Jazeera ជាភាសាអង់គ្លេស* ចុះផ្សាយថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៣។

ឌ. ឯកសារ E387.1.13 (E3/9714) – "Transitional justice time: Uncle San, Aunty Yan, and outreach at the Khmer Rouge Tribunal" ("ពេលវេលាសម្រាប់យុត្តិធម៌អន្តរកាល៖ ពូសាន មីងយ៉ាន និងការផ្សព្វផ្សាយព័ត៌មាននៅសាលាក្ដីខ្មែរក្រហម") Alexander Laban Hinton, *Genocide and Mass Atrocities in Asia: Legacies and Prevention (អំពើប្រល័យពូជសាសន៍ និងអំពើសាហាវយង់ឃ្នងជាទ្រង់ទ្រាយធំនៅទ្វីបអាស៊ី៖ កេរដំណែល និងការបង្ការ)* ឆ្នាំ ២០១៣។

ឍ. ឯកសារ E387.1.14 (E3/9715) – "Justice and Time at the Khmer Rouge Tribunal: In Memory of Vann Nath, Painter and S-21 Survivor", ("យុត្តិធម៌

និងពេលវេលានៅសាលាក្តីខ្មែរក្រហម៖ ការចងចាំរបស់ វ៉ាន់ ណាត ជាជាងគំនូរ និងជាអ្នកនៅរស់រានមានជីវិតពីមន្ទីរ ស-២១") Alexander Laban Hinton, *Genocide Studies and Prevention: An International Journal (ការសិក្សាពីអំពើប្រល័យពូជសាសន៍ និងការបង្ការ៖ ទិនានុប្បវត្តិអន្តរជាតិ)* ឆ្នាំ ២០១៤។

ណ. ឯកសារ E387.1.17 (E3/9716) – "Limits of Memory" ("ព្រំដែននៃការចងចាំ") គេហទំព័រស្តីពីព្រឹត្តិការណ៍ថ្មីៗនៅសាកលវិទ្យាល័យ The New School។

៤. អង្គជំនុំជម្រះច្រានចោលសំណើរបស់ នួន ជា ទាក់ទិននឹងឯកសារ E387.1.15 ("Problems of International Codification – Were the Atrocities in Cambodia and Kosovo Genocide?" ("បញ្ហានៃការរៀបចំក្រមអន្តរជាតិ - តើអំពើសាហាវយង់ឃ្នងនៅកម្ពុជា និងកូសូវ៉ូជាអំពើប្រល័យពូជសាសន៍ឬទេ?") William A. Schabas, *New England Law Review* ឆ្នាំ ២០០១) និង ឯកសារ E387.1.16 ("Seeking justice for the killing fields" ("ស្វែងរកយុត្តិធម៌សម្រាប់វាលពិឃាត") Alex Hinton *កាសែត New York Times* ចុះផ្សាយថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៦)។

៥. ទាក់ទិននឹងឯកសារ E387/1 ដែលជាសំណើរបស់ ខៀវ សំផន អង្គជំនុំជម្រះទទួលយកឯកសារខាងក្រោម ធ្វើជាឯកសារភស្តុតាង៖

ក. ឯកសារ E387/1.3 (E3/9717) – "Yes, indeed! Why did they kill (so many)?" ("បាទ, ពិតណាស់! ហេតុអ្វីបានជាពួកគេសម្លាប់ (ច្រើនយ៉ាងនេះ)?") Henri Locard *កាសែតភ្នំពេញប៉ុស្តិ៍* ចុះផ្សាយថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៥។

ខ. ឯកសារ E387/1.5 (E3/9718) – "Why did they kill? Genocide definition debate continues" ("ហេតុអ្វីបានជាពួកគេសម្លាប់? ការពិភាក្សាដេញដោលពីនិយមន័យនៃអំពើប្រល័យពូជសាសន៍នៅតែបន្ត") Alex Hinton *កាសែតភ្នំពេញប៉ុស្តិ៍* ចុះផ្សាយថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០០៥។

គ. ឯកសារ E387/1.6 (E3/9719) – "Defining genocide" ("កំណត់និយមន័យអំពើប្រល័យពូជសាសន៍") Alex Hinton *កាសែតភ្នំពេញប៉ុស្តិ៍* ចុះផ្សាយថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០៦។

៦. អង្គជំនុំជម្រះកត់សម្គាល់ថា ឯកសារ E387/1.1, E387/1.2 និង E387/1.4 ត្រូវបានទទួលយកជាឯកសារភស្តុតាងនៅត្រង់កថាខណ្ឌ ២.ក ២.ឈ និង ២.ញ ជាឯកសារ E3/9702, E3/9710, និង E3/9711។

៧. សំអាងហេតុជាលាយលក្ខណ៍អក្សរនៃសេចក្តីសម្រេចនេះ នឹងចេញនៅក្នុងពេលវេលាសមស្របខាងមុខ។